## Offering help



១ ធីតា៖ ពិសិដ្ឋ លើករបស់អីហ្នឹង? ដូចធ្ងន់ម៉េះ?
ពិសិដ្ឋ៖ អូ ធីតា សៀវភៅចាស់ៗហ្នឹងអ៊ំា។
ធីតា៖ ម៉ស់ ខ្ញុំជួយលើក។ ម្នាក់ឯងធ្ងន់អ៊ំា។ លើកទៅខាងណាវិញ?
ពិសិដ្ឋ៖ អរគុណ ធីតា។ ដាក់ទៅលើតុនោះទៅ។

២ ធីតា៖ មីង ធ្វើអីហ្នឹង? លាងចានមែន?
មីង៖ អ៊ើ មីងលាងចានហ្នឹងអ៊ំា។
ធីតា៖ ចាំខ្ញុំជួយលាង មីង។ ឆាប់ហើយ។
មីង៖ មិនបាច់អ៊េំ ក្មួយ។ នាំតែប្រឡាក់។ ទៅមើលទូរទស្សន៍ចុះ។
ធីតា៖ អត់អីអ៊េំ មីង។ ខ្ញុំចង់ជួយតាស។ ឥឡូវ មីងលាងទៅ ខ្ញុំអ្នកជូត។ ម៉េចដែរ?
មីង៖ អីចឹងក៏បាន។ នោះក្រណាត់ជូតចាន យកមកជូតម៉ោ ហើយបន្ទុបពីលើគ្នាសិនទៅ
ចាំយកទៅរៀបក្នុងរាវចាននៅខាងក្នុង។
ធីតា៖ ចំាស មីង។

| | |
|---|---|
| ធីតា / ពិសិដ្ឋ | female / male Cambodian name |
| ដូច ... ម៉េះ? | spoken form of ដូច ... ម្ល៉េះ? = It seems so ...! |
| ... ហ្នឹងអ៊ំា | here something like: just [old books] |
| អ៊ំា in ធ្ងន់អ៊ំា | spoken form of ណាស់: [it's] too heavy |
| ធ្វើអីហ្នឹង? | short for កំពុងធ្វើអ្វីនេះ? = What are you doing here? |
| អ៊ើ | yes (used by older people replying to younger ones) |
| មិនបាច់អ៊េំ | not necessary (អ៊េំ is a spoken form of the negation particle ទេ) |
| នាំតែប្រឡាក់ | you'll only get dirty |
| តាស | particle emphasizing the preceding: ខ្ញុំចង់ជួយតាស = But I want to help! |
| ម៉េចដែរ? | How's that? / What do you think? |
| នៅខាងក្នុង | short for នៅខាងក្នុងផ្ទះ = inside the house<br>(the kitchen is often considered to be outside the house) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ដូចវប្បធម៌ផ្សេងដែរ ការជួយអ្នកដទៃពេលឃើញគេកំពុងលំបាកក៏ជាទម្លាប់របស់ខ្មែរដែរ ប៉ុន្តែទម្លាប់មួយទៀតនោះគឺ សុំឲ្យគេជួយដោយត្រង់ៗតែម្តង ជាពិសេសពីមនុស្សអាយុច្រើនទៅកាន់មនុស្សក្មេងៗ។ ប៉ុន្តែ ចំពោះស្ថានភាពដែលត្រូវទទួលរាក់ទាក់ ដូចជាភ្ញៀវមកលេងផ្ទះ គឺគេមិនទម្លាប់ប្រើឲ្យភ្ញៀវធ្វើនេះធ្វើនោះទេ។

| | |
|---|---|
| វប្បធម៌ | culture |
| ដោយត្រង់ៗតែម្តង | directly, straightly |
| មនុស្សក្មេងៗ | younger people (not necessarily children or teenager) |
| ចំពោះស្ថានភាពដែល ... | regarding situations in which ... |
| ទទួលរាក់ទាក់ | to be cordial, to welcome |
| ភ្ញៀវ | guest |
| មកលេងផ្ទះ | to visit one’s home |
| ប្រើឲ្យធ្វើនេះធ្វើនោះ | to tell someone to do this or that |

## Additional dialogue

ធីតា៖ ជប់លៀងនៅផ្ទះកញ្ញាថ្ងៃអាទិត្យហ្នឹង កញ្ញាធ្វើម្ហូបខ្លួនឯងមែន? ឬក៏ទិញស្រាប់?
កញ្ញា៖ ខ្ញុំធ្វើម្ហូបខ្លួនឯងតាស ធីតា។ ទិញស្រាប់ថ្លៃ ហើយខ្លាចអត់សូវស្អាត ញ៉ាំទៅឈឺពោះ។
ធីតា៖ អីចឹង ខ្ញុំទៅជួយធ្វើម្ហូបកញ្ញា ម៉េចដែរ?
ពិសិដ្ឋ៖ ធីតាឯងចេះធ្វើម្ហូបតាំងពីអង្កាល់? តិចទៅៗនាំតែទើសទែង។
កញ្ញា៖ មានណា។ ពិសិដ្ឋចេះតែថាឲ្យធីតា។ ធីតា អរគុណច្រើន។ ចុះធីតាអាចម៉ោម៉ោងម៉ានដែរ?

| | |
|---|---|
| ធីតា / កញ្ញា / ពិសិដ្ឋ | female / female / male Cambodian name |
| ទិញស្រាប់ | to buy cooked, prepared food |
| តាស | particle emphasizing the preceding statement |
| អត់សូវស្អាត | not so hygienic, not very hygienic |
| តាំងពីអង្កាល់? | since when? |
| តិចទៅៗនាំតែទើសទែង | Maybe you’ll only be in the way! |
| មានណា | I don’t think so! (contraction of មិនមានឯណា) |
| ពិសិដ្ឋចេះតែថាឲ្យធីតា | You’re only scolding/making fun of ធីតា, ពិសិដ្ឋ! |
| ម៉ោ | spoken form of មក = to come |
| ម៉ាន | spoken form of ប៉ុន្មាន = how much? (here: what time?) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.